មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការពិនិត្យពិច័យលើឯកសារបន្តទៀត

*វេនឌល ឌីហ្វាល់កូ*

*ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២*

*ប្រែសម្រួលដោយ ដា ផល្លា*

នៅកាលពីថ្ងៃអង្គារ ទី២៤ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់បន្តសួរសំណួរទៅកាន់លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា បន្តពីថ្ងៃម្សិលមិញ ។

## ព្រះរាជអាជ្ញាបន្តសួរសំណួរទៅសាក្សី វ៉ាន់ថាន់ ពៅដារ៉ា

សហព្រះរាជអាជ្ញារងជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាន់ តារាវស្មី បានសួរបន្តពីសហការីអន្តរជាតិរបស់ខ្លួនឈ្មោះ ថារិក អាប់ឌុលហាក់ ដែលបានបញ្ចប់កាលពីម្សិលមិញ ។ រស្មី បានសួរទៅ ដារ៉ា ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាកំណត់ថា ទស្សនាវដ្ដីទង់បដិវត្តន៍ដែលបោះពុម្ពដោយបក្សកុម្មុយនីស្តកម្ពុជាមានយថាភាពយ៉ាងដូចម្តេច? លោក ដារ៉ា បានបកស្រាយថា ការកំណត់ពីយថាភាពរបស់ឯកសារត្រូវឆ្លងកាត់ដំណាក់កាលយូរណាស់ ដូចជាត្រូវត្រួតពិនិត្យមើលភាសាសរសេរនៅក្នុងសៀវភៅនោះ និងត្រូវប្រៀបធៀបភាសានោះទៅនឹងភាសាដែលសរសេរនៅក្នុងឯកសារដើមរបស់ខ្មែរក្រហម ព្រមទាំងពាក្យពេចន៍ដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រើដូចជាពាក្យ«កម្មុច»ជាដើម ។

សំណួរបន្តអំពី«ប្រព័ន្ធទិន្នន័យប្រវត្តិរូប»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បានឆ្លើយថា គោលបំណងសំខាន់របស់ប្រព័ន្ធទិន្នន័យនោះ គឺដើម្បីរក្សាទុកឯកសារប្រវត្តិរូបរបស់យុទ្ធជនខ្មែរក្រហម ដែលប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពេលសួរថាតើប្រភេទ ឯកសារមួយណាដែលមជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកថាជាឯកសារ«សំខាន់ជាងគេ» លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជា «មិនធ្វើការវិភាគណាមួយ»ទៅលើឯកសារទេ តែឯកសារទាំងអស់ត្រូវតែចុះក្នុងបញ្ជី ។ ទាក់ទងទៅនឹងឯកសារប្រវត្តិរូប មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតទម្រង់តាមបទដ្ឋានមួយដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យសម្រាប់ឯកសារនីមួយៗ ជាពិសេសដើម្បីជួយសម្រួលក្នុងការស្វែងរកសាច់ញាតិដែលបានបាត់ខ្លួនកាលពីជំនាន់ខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានសេចក្តី

ណែនាំជាក្រដាសក្នុងការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកុំព្យូទ័រ ។ លោក ដារ៉ា បានបញ្ជាក់ទៀតថា លោកជាអ្នកទទួលខុសត្រូវក្នុងការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកុំព្យូទ័រនេះនិងជាអ្នកបង្ហាត់បង្ហាញបុគ្គលិកក្នុងការធ្វើកិច្ចការនេះ ។ ប្រព័ន្ធទិន្នន័យទាំងអស់ត្រូវបានត្រួតពិនិត្យដោយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ដើម្បីឲ្យមានភាពត្រឹមត្រូវ ។ ភាពត្រឹមត្រូវ គឺជាកិច្ចការសំខាន់ណាស់ ព្រោះសាធារណជន មកមជ្ឈមណ្ឌលឯកសារកម្ពុជារៀងរាល់ថ្ងៃ ដើម្បីស្វែងរកមើលសាច់ញាតិដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធទិន្នន័យ មជ្ឈមណ្ឌលឯកសារកម្ពុជា អាចនឹងផ្តល់ចម្លើយទៅអ្នកដែលបានស្វែងរកគ្រួសារបាន ទោះបីជាអ្នកដែលបាត់ខ្លួននោះទទួលមរណភាពហើយក៏ដោយ ។ សម្រាប់ព័ត៌មានផ្សេងទៀត សាធារណជនអាចមើលគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជាស្រាវជ្រាវបន្ថែម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានប្រព័ន្ធទិន្នន័យជារូបថតដែរ ហើយសាធារណជនអាចស្វែងរកអ្នកដែលបាត់ខ្លួន និងអាចរកមើលទៅលើរូបថតបាន ។ នៅពេលដែលសាធារណជនស្គាល់រូបថតណាមួយថាជាសាច់ញាតិរបស់ខ្លួន មជ្ឈមណ្ឌលឯកសារកម្ពុជានិងសួរពីឈ្មោះម្ចាស់រូបថតនោះ រួចបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ។

ចំពោះកម្មសិទ្ធិផ្លូវច្បាប់នៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បានបញ្ជាក់ថា កម្មសិទ្ធរបស់ឯកសារនោះ គឺអាស្រ័យទៅលើកិច្ចព្រមព្រៀងនិងការអនុញ្ញាតពីអ្នកដែលផ្តល់ជូនឯកសារនោះ ។ នៅពេលសួរថា តើនរណាឬស្ថាប័នណាដែលផ្តល់ "ឯកសារច្រើនជាងគេមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា" ហើយនរណាជាអ្នកទទួលឯកសារទាំងនោះ? លោក ដារ៉ា បានឲ្យដឹងថា បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់សុទ្ធតែមានភារកិច្ចប្រមូលឯកសារទាំងអស់តែឯកសារទាំងអស់ត្រូវត្រួតពិនិត្យដោយរូបលោកផ្ទាល់ ។

ទាក់ទងទៅនឹងការដាក់លេខកូដឯកសារជាវីដេអូ លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានបញ្ជីឈ្មោះខ្សែភាពយន្តដែលអាចរកបាននៅលើគេហទំព័រ ហើយបញ្ជីនោះរួមមានប្រភពដែលខ្សែភាពយន្តនោះទទួលបានផង ។

## ការសួរសំណួរបន្តត្រូវបានផ្តល់នាទីទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី

លោក ពេជ អង្គ សហមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ផ្តើមសួរសំណួរទៅកាន់លោក ដារ៉ា ដោយបញ្ជាក់ថា លោកនឹងសួរដោយមិនឲ្យច្រំដែលទេ ។ ទាក់ទងទៅនឹងឯករាជ្យភាពពីសាកលវិទ្យាល័យយែល លោក ដារ៉ា បានឆ្លើយថា សកម្មភាពស្រាវជ្រាវដំបូងត្រូវបានធ្វើឡើងដោយមានការចូលរួមពីសាកលវិទ្យាល័យយែល ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ ធ្វើការស្រាវជ្រាវពី

អំពើប្រល័យពូជសាសន៍របស់ ។ តែពីរឆ្នាំក្រោយ សាកលវិទ្យាល័យនេះចប់អាណត្តិ មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ផ្តើមធ្វើការស្រាវជ្រាវដោយឯករាជ្យ ។ ក្រោយឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាក្លាយជាស្ថាប័នក្រៅរដ្ឋាភិបាលឯករាជ្យ ។ នៅពេល ពេជ អង្គ សួរអំពីទំនាក់ទំនងជាមួយសាកលវិទ្យាល័យយែល ចៅក្រម និល ណុន បានជំទាស់ដោយបញ្ជាក់ថា សំនួរនេះត្រូវបានសួររួចហើយ លោក ដារ៉ា ក៏បានឆ្លើយរួចដែរ ។ ក្រោយមក ចៅក្រម និល ណុន បានជម្រាបទៅ ពេជ អង្គ សួរសំណួរកុំឲ្យច្រំដែល ។ សំណួរបន្តទៅកាន់ លោក ដារ៉ា ថាតើបានចាត់ទុកខ្លួនឯងជាអង្គការ «ស៊ើបអង្កេត»ដែរឬទេ? លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលប្រើពាក្យ «ស៊ើបអង្កេត» ដើម្បីបកស្រាយពីកិច្ចការរបស់ខ្លួនទេ និយាយឲ្យសាមញ្ញគឺថា មជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកចងក្រងឯកសារពីរបបខ្មែរក្រហម ។ លោក ដារ៉ា បានបន្តទៀតថា លោកបានទទួលការបណ្តុះបណ្តាលពីប្រទេសអូស្ត្រាលីពីរបៀប«កត់ត្រា»និង«ចងក្រង»ឯកសារ ក៏ដូចជាការចុះបញ្ជីឯកសារដើម្បីឲ្យសាធារណជនងាយស្រួលស្រាវជ្រាវរក ។ គោលនយោបាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺមិនត្រូវបកស្រាយនិងវាយតម្លៃចំពោះឯកសារណាមួយទេ ហើយក៏មិនធ្វើការវិនិច្ឆ័យលើបុគ្គលណាម្នាក់ក្នុងបទឧក្រិដ្ឋណាមួយដែរ ។

បន្តសំណួរអំពីការចុះបញ្ជី និងចុះលេខឯកសារ ។ ចំនុចនេះ លោក ដារ៉ា ហាក់បីដូចជាស្ទាក់ស្ទើរ ហើយបកស្រាយថា លោកបានឆ្លើយនឹងសំណួរនេះរួចហើយ ។ លោកបានបញ្ជាក់ថា ជាទូទៅមជ្ឈមណ្ឌលឯកសារកម្ពុជាត្រួតពិនិត្យឯកសារជាក្រដាសទាំងអស់ តែឯកសារជាក្រដាសនោះមិនបានឆ្លងកាត់ការពិសោធន៍តាមនិតិវិជ្ជវិទ្យាទេ ។

បើសិនជាមជ្ឈមណ្ឌលឯកសារកម្ពុជា មានមន្ទិលសង្ស័យចំពោះប្រភពឯកសារ ឬក៏សង្ស័យអំពីយថាភាពរបស់ឯកសារណាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការពិភាក្សាជាមួយអ្នកជំនាញដូចជា សាស្ត្រាចារ្យ ដេវី ឆេនដ៍លើ ជាដើម ដើម្បីជួយក្នុងការកំណត់ពីភាពពិតរបស់ឯកសារនោះ ។ ចំពោះ ឯកសារដែលផ្តល់ជូនទៅអ្នកស្រាវជ្រាវផ្សេងៗមិនបានប៉ះពាល់អ្វីទាំងអស់ ព្រោះឯកសារដែលផ្តល់ជូននោះមិនមែនជាឯកសារដើមទេ ហើយអ្នកស្រាវជ្រាវមិនអាចយកឯកសារនោះចេញក្រៅមជ្ឈមណ្ឌលបានដែរ ។ លោក ដារ៉ា បានឲ្យដឹងថា រាល់ឯកសារថតចម្លងទាំងអស់ដែលបានផ្តល់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺ ថតចម្លងចេញពីឯកសារដើមត្រឹមត្រូវ«រាល់ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់សុទ្ធតែមានយថាភាព» ។

បន្ទាប់មក លោកមេធាវី ពេជ អង្គ បានផ្តល់ឱកាសដល់សហការីអន្តរជាតិរបស់ខ្លួនឈ្មោះ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត ធ្វើការចោទសួរបន្ត ។ មុននឹងសួរសំណួរ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត

បានធ្វើការសុំទោសទៅកាន់ លោក ដារ៉ា ព្រោះគាត់នឹងសួរសំណួរដោយ«សាមញ្ញ» ព្រោះសំណួរដោយសាមញ្ញនោះមានសារសំខាន់ណាស់សម្រាប់តុលាការ ។

ជាដំបូង អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបានប្រើប្រាស់«វិធីសាស្ត្រតាមបែបវិទ្យាសាស្ត្រកម្រិតសាកលវិទ្យាល័យ»ឬទេ? លោក ដារ៉ា បានឲ្យដឹងថា នេះគឺជាអ្វីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមាន«ក្រមសីលធម៌»យ៉ាងជាក់ច្បាស់សម្រាប់បុគ្គលិកដែលបានធ្វើការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមានទីប្រឹក្សាច្បាប់ដើម្បីត្រួតពិនិត្យពីបញ្ជីសំណួរដើម្បីឲ្យត្រឹមត្រូវតាមបទដ្ឋានច្បាប់ និងបុគ្គលិកទាំងអស់បានអនុវត្តតាមគោលការណ៍នេះ ។ ទម្រង់បទដ្ឋាននេះក៏បានបញ្ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីឲ្យជ្រាបផងដែរ ។

លោក ដារ៉ា បានបញ្ជាក់ថា លោកចាត់ទុកខ្លួនឯងថាជាអ្នកជំនាញខាងស្រាវជ្រាវពីប្រវត្តិសាស្ត្រ ព្រោះលោកមានបទពិសោធន៍ខាងកិច្ចការនេះចំនួន១៧ឆ្នាំមកហើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយសាកលវិទ្យាល័យនានារួមមាន សាកលវិទ្យាល័យរ៉ាត់ហ្គើស និងសាកលវិទ្យាល័យថែមផល នៅសហរដ្ឋអាមេរិក ។ នៅពេលសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានឈ្មោះល្បីទេសម្រាប់សាកលវិទ្យាល័យនានានៅបរទេស? លោក ដារ៉ា ឆ្លើយថា គាត់មិនចង់«អួត»ពីកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ អេលីហ្សាប៊ែត បានសួរទៀតថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបានជួយ«បង្ហាត់បង្ហាញ»ពីរបៀបរកមើលឯកសារដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ នៅពេលដែលអ្នកនោះទៅមជ្ឈមណ្ឌលឯកសារកម្ពុជា? លោក ដារ៉ា បាននិយាយថា នរណាក៏ដោយឲ្យតែមកទស្សនាមជ្ឈមណ្ឌលឯកសារកម្ពុជាសុទ្ធតែទទួលបាននូវការណែនាំពីរបៀបស្រាវជ្រាវមើលឯកសារទាំងអស់ ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថា «រាល់អ្នកមកមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ទទួលបាននូវការណែនាំ» ។

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថាជាម្ចាស់ជំនួយមួយដែលបានផ្ដល់ជូនឯកសារទាំងអស់នោះ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាននូវអំណរគុណពីអង្គជំនុំជម្រះនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាស្វាគមន៍រាល់ការផ្ដល់ឯកសារទាំងអស់ទៅគ្រប់ភាគីទាំងអស់ «ដោយសមរម្យតាមពេលវេលា» និងដោយឥតគិតថ្លៃ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានបញ្ហាអ្វីមួយជាមួយអង្គជំនុំជម្រះទេរហូតមកដល់ពេលនេះ ។

**អៀង សារី ហត់នឿយ និងស្នើទៅសម្រាក**

ដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សំណួរនៅពេលនេះ ហើយអង្គជំនុំជម្រះចាប់ផ្តើមប្រកាសសម្រាក នៅវេលាម៉ោង១០:៣០ដូចធម្មតា ។ ស្របពេលនោះ លោក អាង ឧត្តម មេធាវីជាតិរបស់ អៀង សារី បានក្រោកឈរឡើងហើយជូនដំណឹងទៅអង្គជំនុំជម្រះថា អៀង សារី ចង់សុំសិទ្ធិទៅសម្រាក និងតាមដានដំណើរការសវនាការតាមប្រព័ន្ធសោទស្សន៍វិញ ។ ដោយសារនេះជាទម្លាប់របស់ជនជាប់ចោទទៅហើយនោះ អង្គជំនុំជម្រះបានយល់ព្រមនូវសំណើ និងប្រាប់ទៅមេធាវីឲ្យជូនលិខិតសុំជាលាយលក្ខណ៍អក្សរផ្ញើមកអង្គជំនុំជម្រះ ។

## ***សំណួរបន្តទៀតទាក់ទងទៅនឹងចំណាររទៅលើឯកសារ***

ក្រោយពីសម្រាករួច ចៅក្រម ឡាវែ៊ញ ចាប់ផ្តើមសួរទៅ លោក ដារ៉ា នូវសំណួរមួយចំនួនទាក់ទងទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយមានការបង្ហាញរូបឯកសារនៅលើកអេក្រង់ ហើយនៅលើគែមខាងស្តាំនោះមានចំណាររមួយដែរនោះ ចៅក្រមបានសួរអំពីចំណាររនោះ ។ លោក ដារ៉ា បានឆ្លើយថា តាមលោកដឹង ឯកសារនោះគឺជាឯកសារថតចម្លងរបស់ឯកសារ លន់ នល់ “L”របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដំបូងឯកសារនោះត្រូវដាក់នៅខុសកន្លែងដោយដាក់នៅក្នុងឯកសារ“N” ដូច្នេះទើបឃើញមានអក្សរ “N” នៅលើឯកសារនោះ ។

ចំពោះខ្លឹមសាររបស់ឯកសារ លោក ដារ៉ា បានអានពីទីតាំងដែលឯកសារនោះបានឆ្លើយទៅដោយបញ្ជាក់ថា ឯកសារនោះត្រូវបានបញ្ជូនទៅ “បងនួន” ។ លោកបានបញ្ជាក់ថា ការប្រើពាក្យគោរព “បង” នៅក្នុងឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាបញ្ជាក់ថា សារទូរលេខនោះត្រូវបានបញ្ជូនទៅឈ្មោះដែលមានឋានៈខ្ពស់ជាងអ្នកដែលផ្ញើទៅ ។ តាមបទពិសោធន៍របស់លោក “បងនួន” គឺចង់សំដៅទៅលើ នួន ជា ។ លោកបាននិយាយថា លោកមិនបកស្រាយអំពីខ្លឹមសាររបស់សារទូរលេខឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា និងអំពីដំណើរការបញ្ជូនសារនោះទេ ។

បន្ទាប់មក ចៅក្រម ឡាវែ៊ញ បានបង្ហាញពីឯកសារមួយទៀតដោយមានចំណាររនៅលើឯកសារនោះផង ។ ចៅក្រមបានប្រៀបធៀបឯកសារនេះទៅនឹងឯកសារមុនដែលមានភាពខុសគ្នាត្រង់ថា ឯកសារមុនមានចំណាររបន្ថែមទៀតនៅលើគែមខាងស្តាំ ។ លោក ដារ៉ា បានរៀបរាប់ថា ឯកសារដំបូងគឺ ជាឯកសារដែលថតចម្លងចេញពីឯកសារដើម ដោយគ្មានលេខកូដរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅលើនោះទេ ហើយឯកសារថ្មីនេះ គឺជាឯកសារថតចេញពីឯកសារថតចម្លងនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានដាក់លេខកូដនៅលើនោះផង ។ រាល់ឯកសារទាំងអស់ក្រៅពីចំណាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាចំណារដើម ។ រាល់សារទូរលេខទាំងអស់មានអក្សរដែលបញ្ជាក់អំពីលេខទូរលេខ និងលេខវិទ្យុ ហើយលោកក៏មិនដឹងពីអត្ថន័យរបស់“លេខវិទ្យុ”នោះទេ ។

នៅពេលសួរអំពីលេខយោង «១៧០» នៅចុងកំពូលឯកសារនិងអក្សរពណ៌ក្រហមធំៗនៅជិតលេខនោះ លោក ដារ៉ា បានឆ្លើយថា ចំណារនោះចារឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាពេលទទួលបានឯកសារនោះភ្លាមៗ ឯកសារទទួលបានពីបណ្ណសាររបស់គុកទួលស្លែង ហើយលោកមានជំនឿថា ឯកសារទាំងអស់ត្រូវបានដាក់លេខ ព្រោះឯកសារនេះរកឃើញនៅក្នុងបណ្តុំឯកសារជាច្រើន ហើយលេខនោះបញ្ជាក់អំពីទីតាំងនៅក្នុងបណ្តុំឯកសារនោះៗ ឯកសារនេះត្រូវបានបញ្ជូនទៅ «ពូនួន, ពូវ៉ាន់ និង ពូវន» ហើយឈ្មោះនោះគឺសំដៅទៅលើ នួន ជា, អៀង សារី និង វន វ៉េត។

ឯកសារបន្ទាប់មកទៀតដែលចៅក្រម ឡាវ៉ែញ បង្ហាញទៅ លោក ដារ៉ា គឺមានចំណារស្រដៀងគ្នានោះដែរ។ លោកបានបញ្ជាក់ថា ឯកសារដែលបង្ហាញនោះ គឺជាឯកសារថតចម្លងចេញពីឯកសារដើម ដោយមិនមានលេខកូដរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ តែលេខ «១៧៥» ដែលសរសេរនៅលើឯកសារនោះគឺចង់សំដៅទៅលើលេខទំព័រ។ ក្រោយពីសួរចប់ ចៅក្រម ឡាវ៉ែញ បានថ្លែងអំណរគុណដល់លោក ដារ៉ា ហើយក្រោយមកលោកចៅក្រមបានប្រគល់តួនាទីនេះទៅក្រុមការពារក្តីដើម្បីឆ្លើយសំណួរទៅកាន់លោក ដារ៉ា វិញ។

## ក្រុមការពារក្តី នួន ជា ធ្វើការតាំងសំណួរទៅលោក វ៉ាន់ថាន់ ពៅដារ៉ា

ក្រុមការពារក្តីចាប់ផ្តើមសួរដោយមេធាវី សុន អរុណ។ ក្រោយពីសួរចប់ លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារជាងប្រាំសែនទំព័រដល់សាលាក្តីខ្មែរក្រហម ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញមិនទាន់ចុះហត្ថលេខានៅឡើយទេ នេះទាក់ទងទៅនឹងការផ្តល់ឯកសារ ព្រមទាំងយថាភាពរបស់ឯកសារនោះ។

សុន អរុណ បន្តសួរទៅលោក ដារ៉ា ថាតើការផ្តល់ឯកសារដោយមិនមានការចុះហត្ថលេខាត្រឹមត្រឹមជា«ការខុសច្បាប់»ដែរឬទេ? លោក ដារ៉ា បានឆ្លើយថា រាល់ឯកសារដែលបានផ្ញើពីមជ្ឈមណ្ឌលឯកសារកម្ពុជាគឺតាមសំណូមពររបស់អង្គជំនុំជម្រះ។ ក្រោយមក សុន អរុណ បានសួរទៅលោក ដារ៉ា នូវអ្វីដែលលោក ឆាំង យុ បាននិយាយ។ ក្រោយមក ព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណួរនេះ ហើយ មេធាវីរបស់ នួន ជា បានឆ្លើយថា សំណួរនេះចាត់ទុកថា ត្រឹមត្រូវព្រោះលោក ដារ៉ា គឺជាតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយសេចក្តីថ្លែងការណ៍ធ្វើឡើងដោយលោក ឆាំង យុ ក្នុងនាមមជ្ឈមណ្ឌលឯកសារកម្ពុជា។ អង្គជំនុំជម្រះមិនយល់ស្រប ហើយបានស្នើទៅលោក សុន អារុណ ឲ្យសួរសំណួរផ្សេងទៀតដោយមិនត្រូវសំអាងលើសក្ខីកម្មរបស់សាក្សីផ្សេងទៀតទេ។ លោក សុន អរុណ បន្តសំណួរផ្សេង ហើយសំណួរនេះត្រូវជំទាស់ដោយសហព្រះរាជអាជ្ញាដដែល សហព្រះរាជអាជ្ញាបានរំឭកទៅអង្គជំនុំជម្រះថា សំណួរនេះបានសួរដោយផ្អែកលើសក្ខីកម្ម

របស់សាក្សីផ្សេងទៀត ។ មេធាវីជនជាប់ចោទបានសុំទោសដោយអះអាងថា លោកប្រឡូកនឹងសក្ខីកម្មរបស់អ្នកផ្សេងទៀត ។ ចំណុចនេះធ្វើឲ្យអ្នកតាមដានសើច ។

ក្រោយមក សុន អរុណ បានសួរអំពីទស្សនាវដ្ដី «ទង់បដិវត្តន៍» ។ លោក ដារ៉ា បានឆ្លើយថា ទស្សនាវដ្ដីនេះមានគម្របពណ៌ក្រហម ហើយថា ឯកសារថតចម្លងដែលលោកបានអាន គឺជាអក្សរពុម្ព មិនមែនអក្សរសរសេរដោយដៃទេ ។ លោក ដារ៉ា បញ្ជាក់ទៀតថា លោកមិនអាចរៀបរាប់អំពីទំហំទស្សនាវដ្ដីនោះទេ ព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលវាស់ពីកម្រាសរបស់ទស្សនាវដ្ដីដែរ ។

បន្ទាប់មកលោក សុន អារុណ ចង់ប្រាប់ទៅ នួន ជា ដោយចង់ឲ្យលោកសួរសំណួរទាក់ទងទៅនឹងទស្សនាវដ្ដីទង់បដិវត្តន៍ ។ ពេលនោះចៅក្រម និល ណុន និយាយកាត់ហើយបញ្ជាក់ទៅមេធាវីការពារក្ដីថា មិនដើរតាមគន្លងរបស់ខ្លួនទេ ព្រោះទស្សនាវដ្ដីនោះត្រូវបានយកមកពិភាក្សាច្រើនដងមក ហើយមេធាវីគួរតែផ្ដោតលើភ័ស្ដុតាងឯកសារទាក់ទងទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្រោយមកលោក សុន អរុណ បានសួរថាតើ«ប្រភេទ»ឯកសារអ្វីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពីម្ចាស់ជំនួយ ។ លោក ដារ៉ា បានឆ្លើយថា ឯកសារទាំងនេះត្រូវបានត្រួតពិនិត្យតាមរយៈបទដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយរូបលោកផ្ទាល់ជាអ្នកត្រួតពិនិត្យឯកសារទាំងនោះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាពិនិត្យមើលឯកសារទាំងអស់ ដើម្បីបញ្ជាក់ពីយថាភាពរបស់ឯកសារដែលទទួលបាន ។

មេធាវីបានសួរអំពីសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវីបានសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានទំនុកចិត្តប៉ុណ្ណាពីអ្វីដែលបានរៀបរាប់នៅក្នុងសៀវភៅនោះ គឺជារឿងពិត? ហើយមានទំនុកចិត្តបែបណាក្នុងការយកមកប្រើប្រាស់ ដើម្បីយកទៅបង្រៀនសិស្សនៅពេលដែលអង្គជំនុំជម្រះមិនទាន់បានបញ្ជាក់ថា អ្វីដែលបានសរសេរនោះមានលក្ខណៈត្រឹមត្រូវផងនោះ? លោក ដារ៉ា បានបកស្រាយដោយបញ្ជាក់ថា លោកត្រូវបានអញ្ជើញឲ្យនិយាយពីឯកសារប៉ុណ្ណោះ ហើយមិនត្រូវនិយាយពីសៀវភៅដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។

សំណួរផ្សេងទៀត អំពីឯកសារដែលប្រមូលបានទាក់ទងនឹងរបបខ្មែរក្រហម សួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់សង្ស័យថាឯកសារណាមួយ«ត្រូវបានប្រឌិតឡើងដោយបុគ្គលណាមួយ ឬស្ថាប័នណាមួយដែរឬទេ?» លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បានជិទាស់ឯកសារមួយច្បាប់ ព្រោះមានការសង្ស័យថា ឯកសារនោះ គឺមិនពិត ។

*លោក សុន អារុណ បានបន្តសួរទៅមុខទៀតដោយបញ្ជាក់ពីគំនិតរបស់លោកផ្ទាល់ និង«ការស្រាវជ្រាវ»ទាក់ទងទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងរបបកុម្មុយនីស្តផ្សេងទៀត ។ ចំណុចនេះ ធ្វើឲ្យលោកប្រធានចៅក្រម និល ណុន ជំទាស់ជាលើកទីពីរ ព្រមទាំងបានរំឭកទៅមេធាវីរូបនេះឲ្យដាក់ដែនកំណត់អំពីសំនួររបស់ខ្លួនដោយសួរដែលទាក់ទងទៅនឹងឯកសារប៉ុណ្ណោះ មិនត្រូវសួរអំពីគំនិតរបស់ខ្លួនទេ ។*

*បន្ទាប់ពីនោះ លោក សុន អារុណ បានសួរអំពី «សៀវភៅខ្មៅ» ដែលបោះពុម្ពដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៨ ។ ដោយមានការភាន់ច្រឡំខ្លះ ឯកសារនេះត្រូវបានបញ្ចាំងនៅលើអេក្រង់កុំព្យូទ័ររបស់តុលាការ ។ មេធាវីបានសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានសៀវភៅខ្មៅដើមដែរឬទេ? លោក ដារ៉ា បានឆ្លើយថា លោកមិនដឹងថាតើមេធាវីចង់សួរពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឬ យ៉ាងណាព្រោះសៀវភៅនោះមានគម្របខ្មៅដែរ ។ ក្រោយមកចៅក្រមបានជួយបញ្ជាក់មេធាវីដោយ បញ្ជាក់ថា មេធាវីចង់សួរអំពីសៀវភៅខ្មៅ មិនមែនជាសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនោះទេ ។ លោក ដារ៉ា មិនបានឆ្លើយទៅនឹងសំនួរនេះទេ ក្រោយមកអង្គជំនុំជម្រះបានបង្ហាញឯកសារនោះ ទៅលោក ដារ៉ា ដើម្បីឲ្យលោកត្រួតពិនិត្យមើល ហើយសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានសៀវភៅនេះដើមឬទេ?*

*ក្រោយមកអង្គជំនុំជម្រះប្រកាសសម្រាកអាហារថ្ងៃត្រង់ ។*

## នួន ជា ហត់នឿយនិងស្នើទៅសម្រាកនៅបន្ទប់រង់ចាំ

*ក្រោយពីសម្រាកអាហារថ្ងៃត្រង់រួច មេធាវីរបស់ នួន ជា បានជម្រាបទៅអង្គជំនុំជម្រះថា នួន ជា ចង់សុំសិទ្ធិសម្រាក ។ សំណើនេះត្រូវបានយល់ព្រមបើសិនជាមានលិខិតជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយ នួន ជា ផ្ទាល់ ។ ក្រោយមក នួន ជា ត្រូវបាននាំទៅកាន់បន្ទប់រង់ចាំដើម្បីតាមដានដំណើរការសវនាការ ។ ដូច អៀង សារី ដែរ នួន ជា មិនមានវត្តមាននៅក្នុងបន្ទប់សវនាការទេ នៅពេលរសៀលនេះ ហើយនេះក្លាយជាទម្លាប់ទៅហើយសម្រាប់ដំណើរការសវនាការក្នុងសំណុំរឿង ០០២នេះដែរ ។*

## ការបកស្រាយពី «សៀវភៅខ្មៅ» ដែលមានការភាន់ច្រឡំ

*ក្រុមការពារក្តីរបស់ នួន ជា ចាប់ផ្តើមសួរសំណួរនៅពេលរសៀលនេះ ដើម្បីជម្រះពីភាពភាន់ច្រឡំទាក់ទងទៅនឹង«សៀវភៅខ្មៅ» ។ លោក ដារ៉ា បានអះអាងបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារដើម តែឯកសារដែលបានថតចម្លងនេះមិនមែនថតចេញពីឯកសារដើមទេ ព្រោះឯកសារនោះមានលេខកូដនៅពីលើនោះ ។*

## មេធាវីការពារក្តី នួន ជា បន្តការសាកសួរ

លោក ហ្សាស្តេី ប៉ាវ មេធាវីអន្តរជាតិរបស់ នួន ជា ចាប់ផ្តើមសួរសំណួរ។ មុននឹងសួរលោក ហ្សាស្តេី ប៉ាវ បានសុំឲ្យលោក ដារ៉ា បញ្ជាក់ឲ្យច្បាស់ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍ដោយ "សាក្សីផ្សេងទៀត" មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដោយចង់សំដៅទៅលើលោក ឆាំង យុ ដែលជានាយករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោក សុន អរុណ បាននិយាយរួចហើយកាលពីព្រឹកមិញនេះ។ មេធាវីអន្តរជាតិ បានអះអាងថា វាអាចមានចំណុច"មិនគួរឲ្យជឿខ្លះ" ដែលបានសួរសំណួរទៅកាន់លោក ដារ៉ា ដែលជាតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមេធាវីបានអះអាងថា មជ្ឈមណ្ឌលឯកសារកម្ពុជា មិនបានផ្តល់ឱកាសដល់គ្រប់ភាគីទាំងអស់ ឲ្យសួរអំពីសេចក្តីថ្លែងរបស់លោក ឆាំង យុ ទេ ហើយគ្រប់ភាគីទាំងអស់ និងលោក ដារ៉ា សុទ្ធតែដឹងពីសេចក្តីថ្លែងការណ៍នេះ។

ចៅក្រមបានជំនុំគ្នាជាច្រើននាទីមុននឹងចេញសេចក្តីណែនាំ។ ក្រោយមក ចៅក្រម និល ណុន បានបញ្ជាក់ថា សេចក្តីថ្លែងការណ៍របស់លោក ឆាំង យុ គឺ"ទាក់ទងទៅនឹងសាក្សីរូបនេះត្រូវបានកោះហៅឲ្យមកទៅធ្វើសក្ខីកម្មនៅក្នុងអង្គជំនុំជម្រះនេះ" ហើយ"ទាល់តែលោក ឆាំង យុ ត្រូវបានកោះហៅមកម្តងទៀត" ទើបយើងពិភាក្សាពីសេចក្តីថ្លែងការណ៍នេះ។

ក្រោយមក ចៅក្រម និល ណុន សួរថាតើសាក្សីផ្សេងទៀតណាខ្លះទៅដែលបានធ្វើសេចក្តីថ្លែងការណ៍ចំនួនប្រាំដងដែលក្រុមរបស់ នួន ជា ចង់ស្រាវជ្រាវរកនោះ។ មេធាវី ហ្សាស្តេី ប៉ាវ បានបញ្ជាក់ថា ក្រុមការពារក្តីចង់រកមើលសក្ខីកម្មមនុស្សម្នាក់ដែល"អ្នកនៅក្នុងបន្ទប់នេះស្គាល់គ្រប់គ្នា" ហើយថាមនុស្សម្នាក់នេះបានធ្វើសេចក្តីថ្លែងការណ៍ចំនួនប្រាំមួយដង។

ក្រោយពីផ្អាកមួយសន្ទុះ ចៅក្រម និល ណុន បានប្រកាសថា សំណួរនៅពេលនេះគឺសួរអំពីតែឯកសារដែលផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាប៉ុណ្ណោះ ហើយមិនត្រូវសួរដោយសំអាងលើសាក្សីផ្សេងទៀតទេ។ មេធាវី ហ្សាស្តេី ប៉ាវ មិនបានឲ្យស្ថានភាពនោះស្ងប់ស្ងាត់ទេ ដោយបញ្ជាក់ថាលោក ឆាំង យុ មិនមានឈ្មោះក្លែងក្លាយដែលចាត់តាំងដោយអង្គជំនុំជម្រះទេ ហើយលោកនៅមិនច្បាស់ទេថា តើលោកអាចប្រើសេចក្តីថ្លែងការណ៍របស់លោក ឆាំង យុ ដោយរបៀបណានោះ?

ចៅក្រម ឡាវីញ បានសួរទៅមេធាវីរបស់ នួន ជា ថាតើលោកចង់សួរទៅលោក ឆាំង យុ ដែរឬទេ? មេធាវី ហ្សាស្តេី ប៉ាវ បានឆ្លើយថា ក្រុមការពារក្តីរបស់ នួន ជា បន្តជំហររបស់ខ្លួនដោយទាមទារឲ្យលោក ឆាំង យុ ចូលមកធ្វើសក្ខីកម្ម តែក្រុមការពារក្តីអះអាងដែរថា ការសួរទៅលោក ដារ៉ា អំពីសេចក្តីថ្លែងការណ៍របស់លោក ឆាំង យុ ក៏ជាការសមស្របដែរ។

ចៅក្រម ឡាវ៉ែរ៉ិញ បានជំទាស់ទៅនឹងសំណើរបស់ក្រុមមេធាវី នួន ជា ដោយបញ្ជាក់ថា វា «មិនត្រឹមត្រូវ» ទេ ដែលសួរសំណួរដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់សាក្សីផ្សេងទៀត ដែលមិនទាន់បង្ហាញខ្លួននៅក្នុងតុលាការផងនោះ ។

បន្ទាប់មកលោកមេធាវី ហ្សាស្មើ ប៉ាវ ចាប់ផ្តើមសួរសំណួរ ។ សំណួរទីមួយគឺទាក់ទងទៅនឹងតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងនាមជាអង្គការមួយថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមាន «គោលបំណងអ្វីផ្សេងទៀត» ដែរឬទេ ជាជាងអ្វីដែលលោក ដារ៉ា បានរៀបរាប់ខាងលើនោះ? ត្រង់ចំណុចនេះលោក ដារ៉ា បានបញ្ជាក់ថា លោកបានបញ្ជាក់ត្រង់ចំណុចនេះច្បាស់រួចហើយទាក់ទងទៅនឹងគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅពេលសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានដែលធ្លាប់«អះអាងថា ចង់នាំ នួន ជា ទៅកាត់ទោសដែរឬទេ?» លោក ដារ៉ា បានបញ្ជាក់ថា សំណួរនេះមិនទាក់ទងទៅនឹងប្រធានបទទាក់ទងទៅនឹងឯកសារទេ ហើយលោក ដារ៉ា ក៏មិនចង់និយាយពីបញ្ហានេះដែរ ។ ក្រោយមក ចៅក្រមបានរំឭកទៅមេធាវីឲ្យសួរត្រង់ចំណុចទាក់ទងទៅនឹងឯកសារ ។ មេធាវីបានឆ្លើយតបវិញថា សំណួរនេះ គឺចង់ដឹងថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពលំអៀងឬអត់? ហើយចង់ដឹងថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបានថ្លែងថា ចង់កាត់ទោស នួន ជា ឬអត់?

ការទទូចនេះធ្វើឲ្យអង្គជំនុំជម្រះខឹងឡើង ព្រមទាំងបានរំឭកទៅលោកមេធាវីសួរឲ្យត្រូវចំណុច ។ អង្គជំនុំជម្រះក៏បានព្រមានថា បើសិនជាក្រុមការពារក្តីរបស់ នួន ជា សួរមិនចំណុចទេ អង្គជំនុំជម្រះនឹងសន្មត់ថា ក្រុមនេះមិនមានសំណួរអ្វីទេ រួចនឹងប្រគល់នាទីនេះទៅក្រុមផ្សេងទៀតវិញ ។ និយាយរួច មេធាវី ហ្សាស្មើ ប៉ាវ ចាប់ផ្តើមសួរអំពីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពី«គម្រោងយុត្តិសាស្ត្រ» ដោយបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោង និងបន្តប្រមូល«ភស្តុតាង»នៃ«អំពើប្រល័យពូជសាសន៍» និង«បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ» ។ លោក ដារ៉ា បានឆ្លើយដោយជូនដំណឹងទៅអង្គជំនុំជម្រះថា តើលោកត្រូវឆ្លើយនឹងសំណួរនេះឬទេ? ចៅក្រមបានស្នើឲ្យលោក ដារ៉ា ឆ្លើយតបទៅនឹងសំណួរនេះ ។ លោក ដារ៉ា បានឆ្លើយថា ឯកសារនោះ គឺជាផ្ទាំងផ្សព្វផ្សាយដោយបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា តែគាត់មិនចង់និយាយទៀតពីបញ្ហានេះទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងរួម គឺលើកកម្ពស់«ការចងចាំនិងយុត្តិធម៌» ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមិនប្រើពាក្យ«ភស្តុតាង»ទេ តែប្រើប្រាស់ពាក្យ«ប្រមូលឯកសារ»វិញ ។ មេធាវីបានបញ្ជាក់ថា ពាក្យ «ភស្តុតាង» ឃើញមាននៅលើផ្ទាំងផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រោយមក មេធាវីសួរទៅលោក ដារ៉ា អំពីក្រុម«ការទទួលខុសត្រូវ»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក

ដារ៉ា បានឆ្លើយថា គម្រោងនេះប្រមូលព័ត៌មានទាក់ទងទៅនឹងអ្នកដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ហើយព័ត៌មានដែលទទួលបាននោះក៏អាចយក ទៅប្រើប្រាស់ផ្សេងទៀតបានដែរដោយអ្នកផ្សេងទៀត ដូចជាយកទៅបោះពុម្ពជាដើម ។

នៅពេលសួរថា តើព័ត៌មានត្រូវបានប្រើប្រាស់ដោយតុលាការដើម្បីកាត់ទោស នួន ជា ដែរឬទេ? លោក ដារ៉ា បានឆ្លើយថា អង្គជំនុំជម្រះបានស្នើសុំព័ត៌មានខ្លះពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពេលសួរអំពីថា តើព័ត៌មាននោះត្រូវបានប្រមូលមកដើម្បីកាត់ទោស នួន ជា ឬយ៉ាងណា? លោក ដារ៉ា បានឆ្លើយមិនបានឆ្លើយដោយត្រង់ៗទេ តែគាត់បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឯកសារទៅកាន់ស្ថាប័នទាំងអស់ដែលបានស្នើសុំ ។ ក្រោយមក មេធាវីការពារក្តីរបស់ នួន ជា បានបង្ហាញគេហទំព័រ ដោយចុចទៅលើគម្រោងដាក់ឲ្យមានការទទួលខុសត្រូវ ដោយបញ្ជាក់ថា «គម្រោងនេះអាចយកមេដឹកនាំខ្មែរក្រហមទៅទទួលខុសត្រូវពីបទឧក្រិដ្ឋ» ។

មេធាវីការពារក្តី បន្តសួរអំពីបញ្ជីសំណួរដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រើប្រាស់ ដើម្បីសម្ភាស ។ មេធាវីបានបង្ហាញឯកសារថតចម្លងមួយទៅលោក ដារ៉ា ហើយបានសួរថា តើអ្វីទៅដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រើប្រាស់ដើម្បីធ្វើបញ្ជីសំណួរនោះ? លោក ដារ៉ា បានឆ្លើយថា ឯកសារនោះ បានផ្តល់នូវវិធីតាមបទដ្ឋានត្រឹមត្រូវ ដើម្បីប្រមូលព័ត៌មានទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារនោះ ត្រូវប្រគល់ឲ្យទៅអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពេលចុះទៅសម្ភាស ។

ក្រោយពីមើលឯកសារទាំងនោះរួចមក មេធាវី ហ្សាស្តេ ប៉ាវ បានបញ្ជាក់ថា លោកមានការ «ភាន់ច្រឡំ» ដោយការប្រើពាក្យមួយចំនួននៅក្នុងឯកសារនោះដូចជា «អំពើមនុស្សឃាត» «ការធ្វើទារុណកម្ម» «ការរំលោភបំពានសាសនា» «ការបំផ្លាញស្ថានីយ៍វប្បធម៌» និងប្រធានបទរងផ្សេងទៀត ដោយប្រើពាក្យ«អំពើប្រល័យពូជសាសន៍» «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» និង«ឧក្រិដ្ឋកម្មសង្គ្រាម» ។ មេធាវី ហ្សាស្តេ ប៉ាវ បានបញ្ជាក់ដែរថា ឯកសារនោះ «ធ្វើឲ្យគាត់រន្ធត់ចិត្ត ហើយនេះជាផែនការក្នុងការកាត់ទោសបុគ្គលណាមួយ» មិនមែនជាអ្វីដែលហៅថា «ជាការស្រាវជ្រាវប្រវត្តិសាស្ត្រទេ» ។ នៅពេលសួរថាតើលោក ដារ៉ា យល់ស្របទៅនឹងអ្វីដែលបាននិយាយនេះទេ លោក ដារ៉ា បានបញ្ជាក់ថា «ដើម្បីប្រមូលឯកសារ និងព័ត៌មាននានា» មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងនឹងជួយដល់អ្នក «មានបំណង និងស្វែងរកយុត្តិធម៌» ។

ក្រោយមកមេធាវីបានសួរទៅថា តើមាន«កិច្ចប្រជុំផ្ទាល់ខ្លួន»ណាមួយរវាងការិយាល័យសហព្រះរាជអាជ្ញា និងមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ មុននឹងប្រគល់ឯកសារណាមួយនោះ? លោក

ដារ៉ា បានបញ្ជាក់ថា លោកគឺជាអ្នកទំនាក់ទំនងជាមួយអង្គជំនុំជម្រះ ហើយពេលខ្លះមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកិច្ចប្រជុំដោយអនុញ្ញាតិឲ្យគ្រប់ភាគីទាំងអស់ចូលរួម ។

ត្រង់ចំណុចនេះ ព្រះរាជអាជ្ញាបានជំទាស់ដោយបញ្ជាក់ថា សំណួរនោះសួរមិនចំរយៈពេលទេ ។ ចៅក្រម និល ណុន បានអនុគ្គរាគមន៍ ហើយជំទាស់ទៅនឹងព្រះរាជអាជ្ញា ។ ចៅក្រមបានស្នើទៅលោក ដារ៉ា ឲ្យឆ្លើយថា "មាន" ឬ"មិនមាន" ឬក៏"មិនដឹង" ទៅសំណួរទាក់ទងទៅនឹងកិច្ចប្រជុំរវាងការិយាល័យសហព្រះរាជអាជ្ញា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បានឆ្លើយថា លោកមិនដែលបានជួបជាមួយអ្នកតំណាងមកពីការិយាល័យសហព្រះរាជអាជ្ញាទេ ។

ដោយសារជិតអស់ពេលវេលាហើយ មេធាវី ហ្សាស្តេី ប៉ាវ ចង់ឃើញកំណត់ហេតុដែលលោក ដារ៉ា មិនបានបញ្ជាក់ឲ្យបានច្បាស់ ហើយការស្តាប់មិនច្បាស់នេះមិនមែនជាបញ្ហាបកប្រែទេ ។

នៅពេលសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបានផ្តល់បញ្ជីឯកសារទៅការិយាល័យសហព្រះរាជអាជ្ញាសម្រាប់យកមកកាត់ទោសដែរឬទេ? លោក ដារ៉ា បានឆ្លើយថា រាល់ឯកសារដែលផ្តល់ជូនការិយាល័យសហព្រះរាជអាជ្ញាទាំងអស់ត្រូវផ្តល់ជូនក្នុងករណីមានសំណើប៉ុណ្ណោះ ។ ចម្លើយនេះធ្វើឲ្យមេធាវីបញ្ជាក់ថា លោក ដារ៉ា មិនបានឆ្លើយចំសំណួរទេ ហើយនៅមានប្រធានបទមួយចំនួនទៀតដែលគាត់មិនទាន់បានឆ្លើយ ។

ក្រោយមក ក្រុមការពារក្តី នួន ជា បានសួរទៅសំណួរផ្សេងទៀតទាក់ទងទៅនឹងការរៀបចំឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវី ហ្សាស្តេី ប៉ាវ បានសួរថា តើឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានដែលចាត់ថ្នាក់តាមជនជាប់ចោទដែលត្រូវយកមកកាត់ទោសទេ ដូចជា នួន ជា ជាដើម ។ លោក ដារ៉ា បានឆ្លើយថា ក្រោយពីប្រមូលឯកសារបានហើយ ជួនកាលឯកសារនោះត្រូវបានចាត់ថ្នាក់តាមអ្វីដែលបានចារនៅលើនោះ ដូចជាឯកសារដែលត្រូវបានចារដោយឈ្មោះ នួន ជា និង អៀង សារី ជាដើម ។ ពេលសួរថាតើមានសំណុំឯកសារណាមួយនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានសរសេរស្លាកថា "នួន ជា" ដែរឬទេ? លោក ដារ៉ា បានស្នើសុំមើលឯកសារទាក់ទងទៅនឹងសំណួរនេះ ។ ក្រោយមកមេធាវីបានបញ្ជាក់ថា លោកមិនអាចផ្តល់ឯកសារណាមួយទេ ព្រោះលោកមិនមានព័ត៌មាននេះ ហើយលោកចង់ដឹងពីមជ្ឈមណ្ឌលឯកសារកម្ពុជាវិញ ។ ជាថ្មីម្តងទៀត លោក ដារ៉ា មិនបានឆ្លើយចំសំណួរទេ មេធាវីបានឆ្លើយថា លោក ដារ៉ា មិនបានឆ្លើយនឹងសំណួរឲ្យចំណុចនោះទេ ។

បន្ទាប់មក មេធាវីបានសួរអំពីដំណាក់កាលត្រួតពិនិត្យឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បានបញ្ជាក់ថា លោកបានមើលគ្រប់ឯកសារទាំងអស់ដែលយកមកមជ្ឈមណ្ឌលឯកសារ

កម្ពុជា ហើយគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទុកព័ត៌មានអំពីប្រភពរបស់ឯកសារនោះ តែលោកមិនបាននិយាយអ្វីទៀតទេ ។

មេធាវី ហ្សាស្តេ ប៉ាវ បានបកស្រាយនូវអ្វីទាក់ទងទៅនឹងលោក វ៉ាន់ថាន់ ពៅដារ៉ា ក្នុងនាមជាសាក្សីដោយសាពេលនេះលោកអស់ពេលហើយ ។ មេធាវីបានអះអាងថា លោក ដារ៉ា មិនបានឆ្លើយសំនួរទាំងអស់ឲ្យបានពេញលេញក្នុងរយៈពេលនៃការសួរនាំចំនួនពីរថ្ងៃនេះទេ ហើយបានបញ្ជាក់ទៀតថា ក្រុមរបស់លោកចង់ដឹងចម្លើយទៅនឹងសំណួរជាច្រើន ហើយសំណួរទាក់ទងទៅនឹងកិច្ចការគោលនយោបាយ និងឯកសារជាកម្មសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគួរតែសួរទៅលោក ឆាំង យុ វិញប្រសើរជាង ។ មេធាវីបានបន្ថែមទៀតថា អង្គជំនុំជម្រះគួរតែណែនាំឲ្យលោក ឆាំង យុ ផ្តល់បញ្ជីឯកសារមកអង្គជំនុំជម្រះផ្ទាល់ ដោយភ្ជាប់មកជាមួយនូវការផ្ទុកឯកសារទាំងអស់នោះផង ។ ក្រោយមក អង្គជំនុំជម្រះប្រកាសសម្រាកសម្រាប់ថ្ងៃនេះ ។

## ព្រះរាជអាជ្ញាឆ្លើយតបទៅនឹងពាក្យសុំរបស់មេធាវីការពារក្តីរបស់ នួន ជា

ក្រោយពីសម្រាកនៅពេលរសៀល ព្រះរាជអាជ្ញាសូមធ្វើអត្ថាធិប្បាយទៅនឹងសំណើរបស់ក្រុមរបស់ នួន ជា ដែលចង់ឲ្យបង្កើតនូវរបៀបចុះបញ្ជីពីមជ្ឈមណ្ឌលឯកសារកម្ពុជារាល់ឯកសារទាំងអស់ដែលផ្ញើមកពីស្ថាប័នមួយនេះទៅកាន់អង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញាត្រូវបានផ្តល់ពេលជាច្រើននាទីដើម្បីឆ្លើយតប ហើយបានប្រើពេលនេះដើម្បីតវ៉ាថា យុត្តិសាស្ត្រអន្តរជាតិមិនតម្រូវឲ្យផ្តល់ភ័ស្តុតាងទាក់ទងទៅនឹងការរក្សាទុកនិងចាត់ថ្នាក់ឯកសារណាមួយទេ ។ ដើម្បីការពារទៅនឹងអ្វីដែលបានអះអាងនេះ មេធាវី ថារិក អាប់ឌុលហាក់ បានដកស្រង់ករណីជាច្រើនពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។

មេធាវីការពារក្តីរបស់ នួន ជា បានឆ្លើយតបដោយអះអាងថា សក្ខីកម្មរបស់លោក វ៉ាន់ថាន់ ពៅដារ៉ា គឺមានគោលបំណងចង់បញ្ជាក់អំពីយថាភាព និងភាពអាចពឹងពាក់បានរបស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោយពីការធ្វើសក្ខីកម្មនេះ នៅមាន«ចំណុចប្រហោង»នៃការខ្វះព័ត៌មានទាក់ទងទៅនឹងប្រភពរបស់ឯកសារ ។ មេធាវីរូបនេះបានបន្តទៀតថា នេះគឺជាការខ្វះខាតនូវការបកស្រាយទាក់ទងទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្រោយមក ចៅក្រម និល ណុន បានថ្លែងអំណរគុណដល់ភាគីទាំងពីរដែលបានចំណាយពេលបកស្រាយពីបញ្ហានេះ ហើយពេលនេះ ចៅក្រម និល ណុន បានប្រគល់តួនាទីនេះទៅក្រុមការពារក្តីរបស់ អៀង សារី ។

## ក្រុមការពារក្តី អៀង សារី ធ្វើការសាកសួរទៅលោក វ៉ាន់ថាន់ ពៅដារ៉ា

*លោក ម៉ៃឃើល ខារណាវ៉ាស មេធាវីអន្តរជាតិរបស់ អៀង សារី បានក្រោកឈរហើយធ្វើសេចក្តីថ្លែងការណ៍មុននឹងចាប់ផ្តើមសួរសំណួរទៅលោក វ៉ាន់ថាន់ ពៅដារ៉ា ។ ដំបូងលោក ម៉ៃឃើល ខារណាវ៉ាស បានបញ្ជាក់ថា នៅថ្ងៃខាងមុខការតវ៉ាផ្លូវច្បាប់អាចកើតឡើងពេលគ្មានវត្តមានរបស់សាក្សី ជាពិសេសសាក្សីដែលជាមេធាវីដូចលោក វ៉ាន់ថាន់ ពៅដារ៉ា ជាដើម ។ ក្រោយមកមេធាវី ម៉ៃឃើល ខារណាវ៉ាស់ បានចោទលោក ដារ៉ា ថាបាន«និយាយវេរវាយ»ក្នុងសក្ខីកម្មរបស់គាត់ ដោយមិនបានឆ្លើយត្រឹមត្រូវទោលចម្លើយដែលបានឆ្លើយ ហើយមេធាវីបានស្នើទៅអង្គជំនុំជម្រះឲ្យសាក្សីធ្វើការស្បថជាមុនសិនមុននឹងនិយាយ ។*

*ចៅក្រម និល ណុន មិនមានការពេញចិត្តទៅនឹងសំណើនេះទេ ហើយលោកបានបញ្ជាក់ថាអង្គជំនុំជម្រះមិនមានហេតុផលអ្វីនឹងឲ្យស្បថទេ ។*

*ក្រោយមក មេធាវីការពារក្តីរបស់ អៀង សារី ចាប់ផ្តើមសួរសំណួរទៅកាន់លោក ដារ៉ាម្តងទៀតថា តើឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានបានដាក់ឈ្មោះជនជាប់ចោទទាំងបីក្នុងសំណុំរឿង០០២ដែរឬទេ? លោក ដារ៉ា បានបដិសេធថា សំណុំឯកសារបែបនេះមិនមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។*

*បន្តមក មេធាវី ខារណាវ៉ាស បានសួរទៅលោក ដារ៉ា ថា តើលោកមានអាយុប៉ុន្មាននៅពេលដែលលោកចាប់ផ្តើមធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា? សំណួរនេះធ្វើឲ្យមានការគិតគណិតវិទ្យាដើម្បីបូកពីអាយុរបស់លោក ដារ៉ា ក្នុងឆ្នាំ១៩៩៥ ។ ទោះបីជាលោក ដារ៉ា មើលទៅហាក់បីដូចជាធុញទ្រាន់ទៅនឹងសំណួរជាច្រើនរបស់មេធាវី ខារណាវ៉ាស ក៏ដោយ តែលោក ដារ៉ា នៅតែឆ្លើយថាពេលនោះលោកមានអាយុ២៣ឆ្នាំ ។*

*ក្រោយមក មេធាវី ខារណាវ៉ាស បានសួរពីកម្រិតវប្បធម៌របស់លោក ដារ៉ា នៅសាកលវិទ្យាល័យណត្រឺឌេម នៅសហរដ្ឋអាមេរិក ។ ត្រង់ចំណុចនេះ ធ្វើឲ្យយើងដឹងច្បាស់ថា គោលបំណងនៃសំណួររបស់មេធាវី ខារណាវ៉ាស គឺដើម្បីបញ្ជាក់ថាលោក ដារ៉ា ចេះភាសាអង់គ្លេសយ៉ាងល្អ ។ បន្ទាប់ពីសួរនូវសំណួរជាច្រើនរួចមក លោក ដារ៉ា បានបញ្ជាក់ថា លោកទទួលបានសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យណត្រឺឌេម និងចេះនិយាយភាសាអង់គ្លេសតែពេលនេះលោកស្តាប់ជាភាសាខ្មែរដែលបកប្រែដោយអ្នកបកប្រែរបស់អង្គជំនុំជម្រះ ហើយលោកមិនបានស្តាប់សំណួររបស់មេធាវី ហ្សាស្តើប៉ាវ ជាភាសាអង់គ្លេសទេ ។*

*លោកមេធាវី ខារណាវ៉ាស បានសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានទីប្រឹក្សាច្បាប់ ដែរឬទេ? លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានមន្ត្រីច្បាប់ទេ ហើយមុននឹងមកធ្វើ*

សក្ខីកម្មនេះ មិនមាននរណាម្នាក់ណែនាំលោកឲ្យនិយាយទេ។ នៅពេលដែលមេធាវី ខាណាវ៉ាស ព្យាយាមសួរនាំពីចំនុចនេះទៀតចំពោះអ្វីដែលលោក ដារ៉ា និយាយថា «ទីប្រឹក្សាច្បាប់»នោះ លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានបុគ្គលិកដែលជាមេធាវីដូចជា «រូបលោក»ទេ។ លោក ដារ៉ា បញ្ជាក់ទៀតថា លោកមិនបានពិភាក្សាពីការធ្វើសក្ខីកម្មនេះជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ ទេ ព្រោះរូបលោកបានធ្វើដំណើរទៅកាន់ខេត្តផ្សេងៗរហូត កាលពីរសប្តាហ៍មុននេះ។

រាល់សំណួរក្រោយៗមកទៀត មេធាវី ខាណាវ៉ាស ចង់ដឹងអំពីទំនាក់ទំនងរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក ស៊ីវ ហេឌី ដែលជាអ្នកស្រាវជ្រាវពីរបបខ្មែរក្រហមមួយរូប ដែលមានឈ្មោះថាជាទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកក៏ធ្លាប់ធ្វើការនៅអង្គជំនុំជម្រះក្នុងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ។ លោក ដារ៉ា បានបញ្ជាក់យ៉ាងច្បាស់ថា លោកធ្លាប់ជួបលោក ស៊ីវ ហេឌី នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាច្រើនដងនៅពេលដែលលោកមកថតចម្លងឯកសារសម្រាប់សហចៅក្រមស៊ើបអង្កេត។ នៅពេលនោះលោកបាននិយាយជាមួយ លោក ស៊ីវ ហេឌី ក្នុងលក្ខណៈការងារ ព្រោះគាត់បានប្រគល់លិខិតស្នើសុំឯកសារមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកជាអ្នកធ្វើតាមសំណើទាំងអស់នោះ រួចប្រគល់ឯកសារដែលបានស្នើទៅលោក ស៊ីវ ហេឌី។

ទាក់ទងទៅនឹងការបណ្តុះបណ្តាលរបស់លោក ដារ៉ា មេធាវី ខាណាវ៉ាស បានសួរថាតើលោក ដារ៉ា មានចាត់ទុកខ្លួនឯង«ជាអ្នកវិភាគ»ដែរឬទេ? លោក ដារ៉ា បានឆ្លើយថា លោកមានបទពិសោធន៍ច្រើនធ្វើការទាក់ទងនឹងឯកសារ តែលោកសារភាពថា លោកមិនដែលឆ្លងកាត់វគ្គបណ្តុះបណ្តាលណាមួយអំពីការវិភាគ និងការកំណត់ពីយថាភាពរបស់ឯកសារទេ។ ក្រោយមក មេធាវី ខាណាវ៉ាស បានសួរទៀតថា តើហេតុអ្វីបានជាលោកប្រើពាក្យថា «វិភាគ»? លោក ដារ៉ា បានឆ្លើយតបថា ការវិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺកំណត់ត្រឹមថាឯកសារដែលទទួលបាននោះ មានយថាភាព និងទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែរឬអត់? លោកបានបញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាប្រើពាក្យ «វាយតម្លៃ» ជាជាងពាក្យ «វិភាគ»។

ក្រោយមក មេធាវី ខាណាវ៉ាស បានយកទស្សនាវដ្តីស្វែងរកការពិតយកនិយាយហើយបានសួរថា តើលោក ដារ៉ា មានសរសេរអត្ថបទសម្រាប់ទស្សនាវដ្តីនេះ និងឯកសារឯទៀតដែរឬទេ? លោក ដារ៉ា បានឆ្លើយថា លោកបានសរសេរអត្ថបទខ្លះសម្រាប់ទស្សនាវដ្តីនេះ ហើយដំណាក់កាលនៃ

ការសរសេរមានភាពខុសប្លែកគ្នាទាក់ទងទៅនឹងប្រភេទនៃអត្ថបទ លោកបានបញ្ជាក់ទៀតថា លោកមិនអាចបកស្រាយណាមួយទៀតទេ លុះត្រាតែមេធាវីចង់សួរពីអត្ថបទណាមួយ ។

មេធាវី ខាណាវ៉ាស បានសួរទៅលោក ដារ៉ា ដើម្បីឲ្យលោកបញ្ជាក់ម្តងទៀតនូវអ្វីដែលលោកធ្លាប់និយាយរួចហើយថា «រាល់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សុទ្ធតែមានឃុំថាភាពទាំងអស់» ។ លោក ដារ៉ា បានបកស្រាយបញ្ជាក់ថា នេះគឺជាគំនិតរបស់លោកប៉ុណ្ណោះ ដោយផ្អែកលើបទពិសោធន៍របស់លោកកន្លងមក ។ បន្ទាប់មក មេធាវី បានសួរទៅលោក ដារ៉ា ឲ្យពន្យល់ម្តងទៀតអំពីវិធីសាស្រ្ត ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់ ក្នុងការវាយតម្លៃយថាភាពរបស់ឯកសារ ។ លោក ដារ៉ា បានឆ្លើយតបថា ទាក់ទងទៅនឹងយថាភាពរបស់ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា បានសួរទៅបុគ្គលដែលបានផ្តល់ឯកសារនោះដោយផ្ទាល់អំពីប្រភពរបស់ឯកសារទាំងនោះ ។ ក្រោយមកទៀតមេធាវី ខាណាវ៉ាស បានសួរអំពីដំណើរការដែលបានចាត់ការចំពោះឯកសារដែលទទួលបានពីបណ្ណសារដ្ឋានជាតិកម្ពុជា ។ លោក ដារ៉ា បានឆ្លើយតបថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានព័ត៌មាននេះពីអ្នកតំណាងពីបណ្ណសារដ្ឋានជាតិដែលមានភារកិច្ចរក្សាឯកសារទាំងអស់នេះ ។

ត្រង់ចំណុចនេះ មេធាវី ខាណាវ៉ាស បានបញ្ចប់សំណួរ ហើយបានជម្រាបទៅអង្គជំនុំជម្រះថា ពេលនេះម៉ោង៤ៈ០០ ហើយ ដូច្នេះលោកអាចសួរសំណួរនៅព្រឹកស្អែកទៀត ។ អង្គជំនុំជម្រះអរគុណដល់លោក ដារ៉ា ចំពោះសក្ខីកម្មរបស់លោក ហើយអង្គជំនុំជម្រះប្រកាសថា អង្គជំនុំជម្រះតម្រូវឲ្យលោក ដារ៉ា មកកាន់បន្ទប់សវនាការវិញនៅព្រឹកស្អែកទៀត ។ អង្គសវនាការបញ្ចប់សម្រាប់ថ្ងៃនេះ ។

**-ចប់-**